**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...០១...សរណន

*រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០០៦*

# សារាចរណែនាំ

# ស្តីពី

# ការអនុវត្តផែនការក្របខ័ណ្ឌប្រចាំឆ្នាំ

កន្លងមករាជរដ្ឋាភិបាលបានពិនិត្យឃើញថា ក្រសួង ស្ថាប័នមួយចំនួនអនុវត្តផែនការក្របខ័ណ្ឌប្រចាំឆ្នាំនីមួយៗ មិនទាន់បានសមស្របតាមគោលការណ៍ និងនីតិវិធីដែលមានជាធរមាន នាំឱ្យមានបាតុភាពមិនប្រក្រតី និង មិនទាន់មានលក្ខណៈឯកភាពគ្នានៅឡើយ ។ ចំពោះមុខ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងក្របខ័ណ្ឌ និងពង្រឹងការទទួលខុសត្រូវឱ្យកាន់តែខ្ពស់ថែមទៀតក្នុងការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានាដែលកំពុងមានជាធរមាន និងដើម្បីឱ្យស្របតាមទិសដៅនៃកំណែទំរង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលសូមធ្វើការណែនាំបន្ថែម ដូចខាងក្រោម ៖

១-មន្ត្រីដែលទើបបានជ្រើសរើសបញ្ចូលទៅក្នុងក្របខ័ណ្ឌរដ្ឋ ដើម្បីបំរើការងារនៅតាមខេត្ត ត្រូវមានលក្ខខណ្ឌច្បាស់លាស់ស្តីពីរយៈពេលបំរើការងារនៅមូលដ្ឋាន មុននឹងអនុញ្ញាតឱ្យផ្ទេរមកភ្នំពេញ ។ ក្នុងករណីស្នើសុំផ្ទេរមកភ្នំពេញមុនរយៈពេលកំណត់ ត្រូវលុបចេញជាស្វ័យប្រវត្តិពីក្របខ័ណ្ឌរដ្ឋ និងមិនអនុញ្ញាតឱ្យប្រឡងចូលក្របខ័ណ្ឌរយៈពេល ៥ ឆ្នាំ ។

២-ក្នុងការជ្រើសរើសក្របខ័ណ្ឌថ្មី ត្រូវពិនិត្យលទ្ធភាពជ្រើសរើសមនុស្សដែលមានប្រភពនៅមូលដ្ឋានដែលមានតម្រូវការផ្ទាល់ ជៀសវាងការសុំផ្លាស់ប្តូរទីកន្លែងបំរើការងារដែលនាំឱ្យមានការខ្វះក្របខ័ណ្ឌរហូត ។

៣-ការប្រឡងជ្រើសរើសក្របខ័ណ្ឌថ្មី ត្រូវតែធ្វើឱ្យបានរួសរាន់ជៀសវាងការឆ្លងឆ្នាំ ជាពិសេសត្រូវអនុវត្តឱ្យបានមុនខែមិថុនា ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវធ្វើការកែសម្រួលថវិកាឡើងវិញ ។

៤-ក្រសួង ស្ថាប័ននីមួយៗ ត្រូវខិតខំអនុវត្តគោលនយោបាយពង្រាយមន្ត្រីរាជការឱ្យមានប្រសិទ្ធភាពដើម្បីដោះស្រាយកង្វះមន្ត្រីនៅតាមមូលដ្ឋាន ។/.

៥-ក្រសួង ស្ថាប័ននីមួយៗ ត្រូវផ្ញើបញ្ជីមន្ត្រីជាប់កិច្ចសន្យានិងពលករអណ្តែតមកអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដើម្បីបង្កើតជាមូលដ្ឋានទិន្នន័យមួយច្បាស់លាស់ សំរាប់ការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព ។

ទទួលបានសារាចរណែនាំនេះ ក្រសួង ស្ថាប័នទាំងអស់ ត្រូវសហការ និង ចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ។/

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

សុខ អាន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន និងខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ